**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៥៧៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកែសម្រួលមាត្រា ១ នៃអនុក្រឹត្យលេខ ៣១ អនក្រ.តត ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០១២ ស្តីពី ការតែងតាំងសមាជិកក្រុមប្រឹក្សាភិបាលនៃមជ្ឈមណ្ឌលជាតិពិសោធន៍សុខាភិបាល

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២៩៧/៥១ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ ០៦ អនក្រ.បក ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០០៨ ស្តីពីការប្រែក្លាយមជ្ឈមណ្ឌលជាតិពិសោធន៍សុខាភិបាល ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៣១ អនក្រ.តត ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០១២ ស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាភិបាលនៃមជ្ឈមណ្ឌលជាតិពិសោធន៍សុខាភិបាល
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល

## សម្រេច

**មាត្រាមួយ.-**

មាត្រា១ នៃអនុក្រឹត្យលេខ ៣១ អនក្រ.តត ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០១២ ស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាភិបាលនៃមជ្ឈមណ្ឌលជាតិពិសោធន៍សុខាភិបាល ត្រូវបានធ្វើការកែសម្រួលដូចតទៅៈ

**មាត្រា១.- ថ្មី**

ត្រូវបានតែងតាំងសមាសភាពក្រុមប្រឹក្សាភិបាល នៃមជ្ឈមណ្ឌលជាតិពិសោធន៍សុខាភិបាល ដូចមានរាយនាមខាងក្រោមៈ

| | | |
|---|---|---|
| ១-ឯកឧត្តម **សុខ ផេង** | តំណាងក្រសួងសុខាភិបាល | ប្រធាន |
| ២-ឯកឧត្តម **សេខ លីមនៅ** | ឥស្សរជនមានចំណេះដឹង និងបទពិសោធន៍ខាងវិទ្យាសាស្ត្រសុខាភិបាល និងការងារមន្ទីរពិសោធន៍ជាតិនិងអន្តរជាតិ | សមាជិក |
| ៣-លោកជំទាវ **ឱ វណ្ណឌីន** | តំណាងអគ្គនាយកដ្ឋានបច្ចេកទេសសុខាភិបាល | សមាជិក |
| ៤-ឯកឧត្តម **ហាង្ស ម៉ឺន** | តំណាងក្រសួងពាណិជ្ជកម្ម | សមាជិក |
| ៥-លោកស្រី **ឆាយ សំឡៀង** | តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៦-លោក **ឯក វីរះជេដ្ឋ** | តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ៧-លោក **អ៊ិន សំបូរ** | តំណាងក្រសួងឧស្សាហកម្មនិងសិប្បកម្ម | សមាជិក |
| ៨-លោក **ខិន ឆាយ** | តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ៩-លោកស្រី **ឃួន វិទ្យាវណ្ណ** | នាយកមជ្ឈមណ្ឌលជាតិពិសោធន៍សុខាភិបាល | សមាជិកស្វ័យប្រវត្តិ |
| ១០-លោក **ទេព ភីឡា** | តំណាងបុគ្គលិកមជ្ឈមណ្ឌលជាតិពិសោធន៍សុខាភិបាល | សមាជិកស្វ័យប្រវត្តិ។ |

**មាត្រាពីរ.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រាបី.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួលៈ**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រាបី
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ